# ៤— រឿងគង់ហ៊ាន (១)

កាលពីព្រេងនាយ មានមនុស្សម្នាក់ ឈ្មោះគង់ មានប្រពន្ធពីរ ។ មួយឈ្មោះនាងអាំ មួយឈ្មោះនាងគំ ។ ថ្ងៃមួយអ្នកគង់នាំប្រពន្ធទាំងពីនាក់ទៅសួរបងប្អូននៅស្រុកឆ្ងាយ ។ តាមផ្លូវនៅស្រុកនោះ មានខ្លាសាហាវ ។ អ្នកគង់បណ្ដើរប្រពន្ធទាំងពីរនាក់ ទៅដល់ព្រៃធំមួយ ជិតស្រុកគេ, ព្រៃនោះតែងមានខ្លាដេញខាំមនុស្សក្របី គោ ស៊ីតែរឿយ ៗ ។ លុះអ្នកគង់ទៅដល់កន្លែងនោះ ខ្លាក៏ស្ទុះដេញ ស្រែកសន្ធាប់ពីចម្ងាយមក ។ អ្នកគង់រត់ចូលរូងឈើ ញ័រដៃញ័រជើង រាកនោមព្រោះភ័យណាស់ ។ នាងអាំនិងនាងគំ ខំព្រួតគ្នាវាយខ្លានោះស្លាប់ទៅ ។

ឯអ្នកគង់ ឃើញប្រពន្ធវាយខ្លាស្លាប់ហើយ បានស្ទុះអ៊ឹមចេញពីរូងឈើមក យកដំបងវាយខ្លាស្លាប់ស្រាប់នោះថែមទៀត ។ ប្រពន្ធទាំងពីរបន្ទោសប្ដីថា “ខ្លាគេវាយងាប់ហើយ ធ្វើជាមកវាយថែមទៀត ប្រុសអី ។

កំសាកញីដូច្នេះ” ។ អ្នកគង់ ជេរបំពានទៅប្រពន្ធថា “មិនដែលមានស្រីណាវាយខ្លាស្លាប់ទេ មានតែប្រុស ទើបហ៊ានវាយខ្លា ទាល់តែស្លាប់” ហើយអ្នកគង់ក៏បានបោចវល្លិចងខ្លានោះ នាំប្រពន្ធសែងចូលទៅក្នុងស្រុក ។ អស់អ្នកស្រុកឃើញអ្នកគង់សែងខ្លាមក គេបបួលគ្នាទៅមើលពាសពេញហើយគេសួរថា “អ្នកឯង ធ្វើដូចម្ដេច បានជាបានខ្លានេះ ត្បិតខ្លានេះសាហាវណាស់ វាតែងតែខាំមនុស្សម្នាក្របីគោ ស៊ីច្រើនណាស់ហើយ” ។ ប្រពន្ធអ្នកគង់ក៏និយាយប្រាប់អ្នកស្រុកថា “អ្នកគង់គាត់ឃើញខ្លាវាបោលមក គាត់រត់ចូលក្នុងរូងឈើ ខ្ញុំពីរនាក់ជាស្រី ៗ

---

១ ច្បាប់សរសេរដៃ នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យលេខ C.20B របស់លោក E Aymonier ចាត់ការប្រមូលក្រង ទំព័រ ២៦ ខាងភាសាខ្មែរ និងកម្ពុជសុរិយាលេខ៤៤៦ ឆ្នាំ ១៩៣៧ គ្មានឈ្មោះអ្នករៀបរៀងទេ ។

ព្រតគ្នាវាយខ្លាទាល់តែស្លាប់ ។ អ្នកគង់ឮប្រពន្ធនិយាយប្រាប់គេដូច្នោះ ក៏បញ្ចោរ រំលោភទៅលើប្រពន្ធថា " មិនដែលមានស្រីណាខ្លាំងពូកែ ហ៊ានវាយខ្លាស្លាប់ទេ មានតែប្រុសទើបខ្លាំងពូកែ ហ៊ានវាយខ្លាឲ្យស្លាប់បាន " ។ អ្នកគង់ ក៏អួតប្រាប់ អ្នកស្រុកថា " កាលដែលខ្លា វាស្ទុះមកនឹងខាំដូច្នេះ ខ្ញុំផាក់ស្មៀតគុនដូច្នេះបាន ផាវាយវាបាន " ហើយអ្នកគង់ ធ្វើជាលោតគុនវាយខ្លា ឲ្យអ្នកស្រុកមើល ។ ឯ អស់អ្នកស្រុក កោតខ្លាចអ្នកគង់រាល់គ្នា ហើយឲ្យឈ្មោះថា " គង់ហ៊ាន " តាំងពី ថ្ងៃនោះមក ឮល្បីឈ្មោះគង់ហ៊ាន ជាអ្នកពូកែ ចេះគុនវាយខ្លាស្លាប់ ។ រឿងនេះ ជ្រាបដល់ស្ដេច ។ ក៏ឲ្យយកទៅចិញ្ចឹមធ្វើជាសេនាសម្រាប់ច្បាំងសង្គ្រាម ។

លុះយូរបន្តិចទៅ ចួនជា មានសឹកគេលើកមកច្បាំងយកនគរ ស្ដេចទ្រង់ប្រើគង់ ហ៊ានឲ្យទៅច្បាំង ។ គង់ហ៊ាន ឮស្ដេចទ្រង់ប្រើឲ្យទៅជួយច្បាំងសឹកដូច្នោះ ភ័យ ណាស់ ពុំដឹងបើគិតដូចម្ដេច នឹងមិនទៅច្បាំងមិនបាន ត្បិតស្ដេចទ្រង់ប្រើហើយ ហើយខ្លួនបានទាំងល្បីឈ្មោះជាអ្នកខ្លាំងពូកែផង ត្រឡប់មកវិញ ដេកសន្ធឹកសន្ធៃ អត់បាយ ។ ប្រពន្ធទាំងពីរនាក់ចូលទៅសួរថា ម្ដេចបានជាអ្នកដេកអត់បាយដូច្នេះ មានបើហេតុភេទអ្វី ប្រការដូចម្ដេច ? ។ គង់ហ៊ានប្រាប់ថា ត្បិតស្ដេចទ្រង់ប្រើ បងឲ្យទៅច្បាំងសឹក ឥឡូវនេះ បងខ្លាចសឹកនោះណាស់ មិនដឹងបើគិតដូចម្ដេចទេ ប្រពន្ធឆ្លើយឡើងថា អ្នកកុំព្រួយចិត្ត ធានាលើខ្ញុំទាំងអស់អ្នកក្រោកឡើង ពិសា បាយឲ្យឆ្អែត ងូតទឹកឲ្យស្រួលខ្លួនចុះ ។ គង់ហ៊ានឮប្រពន្ធលួងលោមដូច្នោះ បានធូរក្នុង ចិត្ត ក្រោកឡើងងូតទឹក ស៊ីបាយ រៀបគ្រឿងប្រដាប់ទៅច្បាំង, លុះរៀបរួច ហើយដល់បានពេលាល្អ ក៏ចូលទៅក្រាបបង្គំលាស្ដេចចេញទៅច្បាំង, យកទាំង ប្រពន្ធទៅផង ។ គង់ហ៊ានជិះខាងក្បាលដំរី ប្រពន្ធជិះខាងក្រោយ មានរេហ៍ពល ហែហមអមមុខក្រោយជាក្បួនទ័ព គ្រៀបគ្រាពាសពេញ លុះជិះទៅជិតខ្លាំងសត្រូវ មើលឃើញច្បាស់ប្រាកដ គង់ហ៊ានភ័យណាស់ លេចអាចម៍លេចនោមញ័រដៃជើង ដូចគេអង្រួនក្បាលដំរី ។ ឯដំរីគិតស្មានថា គេអង្រួនឲ្យខ្លួនបោលចូល ក៏ចេះតែ បោលសម្រុកចូលទៅ មុនរេហ៍ពលទាំងអស់គ្មាននរណាតាមទាន់ ។

ឯខ្មាំងសត្រូវ ឃើញគង់ហ៊ានបំបោលដំរីចូលដូច្នោះ គិតស្មានថាបេទីពនេះពូកែណាស់ ក៏បាក់ទឹកចាញ់ រត់យកតែព្រះអាយុដោយខ្លួនទៅ ។ គង់ហ៊ាន ឃើញខ្មាំងរត់ទៅអស់ ក៏ធ្វើជាអួតក្អេងក្អាង ឲ្យអស់នាហ្មឺននិងរេហ៍ពលកោតខ្លាច ។ អស់នាហ្មឺន ឃើញគង់ហ៊ានលេចអាចម៍ដាក់ក្បាលដំរី ស្អុយពាសពេញដូច្នោះ គេសួរថា « លោកមេទ័ព ថ្វីក៏លេចលាមកដូច្នេះ ? » ។ គង់ហ៊ានឆ្លើយឡើងថា « បើកំពុងតែច្បាំងនឹងសត្រូវហើយឈឺផ្ដៃ នឹងចុះទៅដោះទុក្ខសត្វឯណាបាន មានតែដោះទុក្ខសត្វលើក្បាលដំរីដូច្នេះឯង បើរវល់តែដោះទុក្ខសត្វ ខ្មាំងវាមិនកាប់ស្លាប់ឥតអំពើទៅហើយ ឬ ? »

អស់នាហ្មឺននិងរេហ៍ពល ឮគង់ហ៊ាននិយាយដូច្នោះ, អ្នកខ្លះមានប្រាជ្ញា គេដឹងថា គង់ហ៊ានខ្លាច, អ្នកខ្លះមិនសូវមានប្រាជ្ញា ក៏កោតខ្លាចគង់ហ៊ានណាស់ ។ ឯគង់ហ៊ាន បានឈ្នះទ័ព ត្រឡប់ចូលមកក្នុងនគរវិញ ហើយចូលទៅក្រាបថ្វាយបង្គំស្ដេច ។

ស្ដេចទ្រង់ជ្រាបថា គង់ហ៊ានទៅច្បាំងឈ្នះ ដេញខ្មាំងរត់ខ្ចាត់ខ្ចាយអស់ទៅ ទ្រង់ត្រេកអរណាស់ ទ្រង់ព្រះរាជទានយសសក្តិជានាហ្មឺនធំ ហើយ ព្រះរាជទានព្រះរាជទ្រព្យ គ្រឿងបណ្ណាការជាច្រើន ។

តាំងអំពីថ្ងៃនោះមក គង់ហ៊ាន រឹតតែអួតខ្លាំងពូកែក្អេងក្អាងឡើងទៀត ។

# ២៥- រឿង បុរសកុហក ៤ នាក់(១)

កាលពីព្រេងនាយ មានបុរសកុហក ៤ នាក់ មកជួបជុំគ្នា រួមគំនិត គិតដើរទៅរកឆបោកបញ្ឆោត យកទ្រព្យសម្បត្តិគេ នៅគេហដ្ឋាន ឆ្ងាយពីលំនៅរបស់ខ្លួន, ព្រមព្រៀងគ្នាស្រេចហើយ ក៏នាំគ្នាដើរទៅ, លុះទៅយូរបន្តិច បានជួបប្រទះនឹងតាចាស់ដូនចាស់ពីរនាក់ ជាអ្នកធ្វើចម្ការកប្បាស នៅក្បែរមាត់ទន្លេមួយដាច់ឆ្ងាយពីស្រុកភូមិគេ ។ បុរសកុហក ៤ នាក់នោះ បានដឹងដំណឹង ថា តាចាស់ដូនចាស់ ជាអ្នកមានទ្រព្យសម្បត្តិច្រើនគ្រាន់បើ ក៏គិតគ្នា ថា « យើងត្រូវនាំគ្នាឈប់ទៅទីនេះ ដើម្បីភូតកុហក យកទ្រព្យសម្បត្តិតាចាស់ដូនចាស់នេះឲ្យបាន » បុរស ៤ នាក់នោះ ទៅដល់សួរតាចាស់ដូនចាស់ថា“ ឱ ! តាយាយអើយ ! យើងខ្ញុំទាំង ៤ នាក់នោះ មកពីស្រុកឆ្ងាយណាស់ ខំត្រាច់ដើររកអ្នកឯណា ដែលចេះដឹង ព្រោះយើងខ្ញុំ ចង់ដឹងរឿងព្រេងពីបុរាណនាយមក, តែវេលានេះ បានមកជួបនឹងតាយាយ ។ ប្រហែលជាចេះដឹងរឿងបុរាណមកខ្លះមិនខានបើដូច្នេះ សូមតាយាយមេត្តានិទានរឿងព្រេងអ្វីមួយ ឲ្យចៅស្តាប់បន្តិច » ។ តាចាស់ដូនចាស់ ក៏ឆ្លើយតបទៅបុរសទាំង ៤ នាក់វិញ ថា « ចៅអើយ ចៅ ! តាំងពីក្មេងដល់ចំណាស់ប៉ុណ្ណេះហើយ តាយាយ គ្មានចេះរឿងព្រេងអ្វីទេ សូមចៅអញ្ជើញទៅរកសួរអ្នកឯទៀតចុះ » ។ បុរសទាំង ៤ នាក់ ក៏ជម្រាបទៅតា–

---

១- កម្ពុជសុរិយាលេខ ៧-៨-៩ ឆ្នាំ ១៩៣៧ ទំព័រ ១២២ គ្មានឈ្មោះអ្នករៀបរៀងទេ ។

យាយវិញ ថា « នុ ! តាយាយអើយ ! បើប្រសិនជាមានគេចេះរឿងព្រេងនោះ តាយាយ ចង់ស្តាប់ឬទេ ? » ។ « នុ ! ចៅអើយ ! តាយាយ ចង់ស្តាប់ពេកាស់តែរកអ្នកណាចេះគ្មាន» ។ បុរសទាំង ៤ នាក់ ក៏ផ្ដាប់ទៅតាយាយវិញ ដោយកិច្ចកល បង់នឹងបោកយកទ្រព្យសម្បត្តិតាចាស់ជូនចាស់នោះ ឲ្យបានដោយងាយ ថា « យើងខ្ញុំទាំង ៤ នាក់នេះ ចេះខ្លះដែរ ព្រោះបានដឹងពីជីតាខ្ញុំ គាត់និទានប្រាប់, តែរឿងនេះ បើនិយាយទៅកាលណា តាយាយ ត្រូវតែជឿ ទើបខ្ញុំនិទានប្រាប់បាន » ។ តាយាយ ក៏ព្រមព្រៀងឲ្យបុរសទាំង ៤ នាក់នោះនិយាយ ។

បុរសទី ១ ចាប់អធិប្បាយរឿងកុហកជាដំបូងឡើងថា : កាលខ្ញុំនៅក្នុងផ្ទៃម្តាយខ្ញុំបានចំនួន ៣ ខែ ម្តាយខ្ញុំ គាត់ចង់ពិសាផ្លែទុរេននៅមុខផ្ទះខ្ញុំ ដើមវា មានកំពស់ប្រហែល ៨ ព្យាម ហើយមានផ្លែតែមួយផង គាត់មិនដឹងជាគិតដូចម្តេច នឹងបានផ្លែឈើនោះមកពិសា ។ លុះខ្ញុំបានដឹងថា គាត់ចង់ពិសាផ្លែនោះ ខ្ញុំក៏ចេញពីផ្ទៃគាត់ តាមទ្វារបាស ទៅឡើងបេះទុរេននោះ យកមកជូនគាត់ពិសា, រួចស្រេច ខ្ញុំត្រឡប់ចូលទៅក្នុងផ្ទៃគាត់វិញ ។

បុរសទី ២ ថា: កាលខ្ញុំនៅក្នុងផ្ទៃម្តាយខ្ញុំ បានចំនួន ៦ ខែ ឃើញគាត់នឿយហត់លំបាកនឹងធ្វើស្រែ ចម្ការ ច្បារដំណាំពេក ខ្ញុំចេញពីផ្ទៃគាត់មក នៅធ្វើស្រែចម្ការ ឃ្វាលគោ ក្របី ដណ្តាំបាយ ដងទឹក ជំនួសគាត់ ពីព្រឹកព្រហាម លុះល្ងាច, អស់ការធ្វើ ខ្ញុំចូលទៅក្នុងផ្ទៃម្តាយខ្ញុំវិញ ជារៀងរាបដរាបមក ។

បុរសទី ៣ ថា «នុ! តាយាយអើយ ខ្លួនខ្ញុំនេះ ជាទេវបុត្រ ច្យុតចុះមកចាប់បដិសន្ធិនឹងម្តាយខ្ញុំសព្វថ្ងៃនេះ ខ្ញុំចេញពីទ្វារមាសវេលាណា បានមកបនៅបម្រើគាត់ សព្វសារពើ, ដល់ខ្ញុំចាស់ទៀបនឹងស្លាប់ ខ្ញុំសុំចូលទៅក្នុងផ្ទៃម្តាយខ្ញុំវិញ ដើម្បីកុំឲ្យស្លាប់ទាន់ហើយកើតម្តងទៀតឲ្យបានជាក្មេងឡើងវិញ ។

បុរសទី ៤ ថា : ខ្លួនខ្ញុំនេះ ចាប់តាំងតែចេញពីផ្ទៃម្តាយកាលណាមក ខ្ញុំរក្សា

សីល ៥ ចាំសីល ៨ តែសីលខ្ញុំ ប្លែកពីសីលអ្នកទាំងពួងចង់ផឹកស្រា ជក់អាភៀន សម្លាប់ជីវិតគេ ក៏បាន, លុះដល់ខ្ញុំស្លាប់ទៅ ៗ កើតជាទេវតា សោយរាជសម្បត្តិនៅឋានសួគ៌ ។

បុរសទាំង ៤ នាក់នោះ និយាយភូតកុហកគ្រប់គ្នាហើយ ក៏សួរទៅតាចាស់ជូនចាស់ ថា « រឿងខ្ញុំនិទានជំរាបទាំងប៉ុន្មាននេះ តើតាយាយជឿឬទេ ? » ។ តាយាយ ឆ្លើយតបទៅវិញ ថា « រឿងនោះ តាយាយ ជឿហើយចៅ ! » តែក្នុងគំនិតគាត់ទាំង ២ នាក់ គិតឃើញជាស្រេចថា « បុរសទាំងនេះ សុទ្ធតែនិយាយកុហកទាំងអស់ » ។

ដល់បុរសទាំង ៤ នាក់នោះ ទាល់ប្រាជ្ញា ក៏ឲ្យតានោះ និយាយរឿងប្រាប់ម្តងវិញ, ប៉ុន្តែ មុននឹងនិយាយរឿង តាចាស់នោះ គាត់បានសន្យាដូចបុរសទាំង ៤ នាក់នោះដែរ; លុះព្រមព្រៀងទាំងអស់គ្នាទើបតាចាស់និយាយ ។

តាថា « ឱ ! ចៅអើយ ! កាលតានិងយាយ មកធ្វើចម្ការកប្បាសនេះបាន ៥-៦ ឆ្នាំ មានទ្រព្យសម្បត្តិ ប្រាក់ មាស ល្មមនឹងចិញ្ចឹមចៅទាំង ៤ នាក់នេះបាន; តែនៅឆ្នាំមួយមុននោះ កប្បាសមិនផ្លែសោះ មិនដឹងជារឿងហេតុអ្វី, មានមួយថ្ងៃ តាដើររុកក្នុងចម្ការទៅ ឃើញដើមកប្បាស ១ ដើម ទំហំប៉ុនដើមត្នោត មានផ្លែមួយធំ តាក៏ឡើងបេះយកមកផ្ទះ, ដល់តានិងយាយនាំគ្នាបកមើល ឃើញមានគ្រាប់ ៤ ក្នុងមួយគ្រាប់ ៗ មានកុមារម្នាក់ ៗ គ្រប់គ្រាប់ទាំង ៤, តាបានឲ្យយាយគាត់បំបៅបីបាច់រក្សា, លុះដល់កុមារទាំង ៤ នាក់នោះ ធំវេលាណាឡើង ក៏នាំគ្នារត់ចោលតានិងយាយទាំងអស់ទៅ, ឥឡូវ តាឃើញចៅទាំង ៤ នាក់នេះត្រឡប់មកវិញហើយ ។

បុរសទាំង ៤ នាក់ ភិតភ័យខ្លាំង ក៏នាំគ្នាឆ្លើយប្រកែកទៅនឹងតាចាស់ជូនចាស់វិញ ថា « មិនមែនទេ » ។ តាយាយសួរទៅវិញ ថា " ហេតុអ្វី ក៏ចៅថា មិនមែន, បើចៅ ចេះតែប្រកែកយ៉ាងនេះ ទុះឃើញថា ទាស់ខុសនឹងកិច្ចសន្យាហើយ, បើដូច្នេះ ត្រូវចៅទាំង ៤ នាក់ មកនៅបម្រើតា ទើបត្រូវនឹងពាក្យសន្យា " ។ បុរសកុហក ៤ នាក់ គេចមិនរួច ក៏នៅបម្រើតាយាយទៅ។

**ពាក្យច្រើនតួត ចាញ់អាត្មា**